**សូមក្រាបបង្គំទូលថ្វាយ**

**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល**

**បពិត្រ សម្តេចព្រះវររាជមាតា ជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត**

ខណៈនេះ ទូលព្រះបង្គំជាខ្ញុំ និងភរិយា មានសេចក្តីក្រៀមក្រំ និងក្តុកក្តួលក្នុងចិត្តយ៉ាងក្រៃលែង ដោយទទួលដំណឹងថា **សម្តេចរាជបុត្រីព្រះរាម នរោត្តម បុប្ផាទេវី** ឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រ សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ និងជាអតីតរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ទ្រង់សោយព្រះទីវង្គត់ នៅថ្ងៃចន្ទ ៧រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង១២:៣០នាទី ក្នុងព្រះជន្មាយុ៧៧ព្រះវស្សា ដោយព្រះរោគាពាធ ។

ក្នុងឱកាសប្រកបដោយសមានទុក្ខនេះ ទូលព្រះបង្គំជាខ្ញុំ និងភរិយា សូមព្រះបរមរាជានុញ្ញាតចូលរួមរំលែកនូវព្រះមរណទុក្ខ ប្រកបដោយអនិច្ចលក្ខណធម៌ដ៏ជ្រាលជ្រៅជាមួយ**អង្គសម្តេចម៉ែ ជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ដោយក្តីសង្វេគ សោកស្តាយ ស្រណោះ អាឡោះអាល័យ ស្ទើរកទីបំផុតគ្មាន ព្រោះថាការបាត់បង់ **សម្តេចរាជបុត្រីព្រះរាម នរោត្តម បុប្ផាទេវី** គឺជាការបាត់បង់ដ៏ធំធេងបំផុត នូវតួអង្គពហុជំនាញក្នុងវិស័យវប្បធម៌ អរិយធម៌ជាតិខ្មែរ ជាដួងព្រលឹងរឹងមាំខ្លាំងក្លា ពិសេសតាំងពីសម័យសង្គមរាស្ត្រនិយម ដ៏ឧត្តុង្គឧត្តម ដែលមានព្រះរាជបុត្រី អង្គព្រះមហាក្សត្រដ៏ឆ្នើម ព្រះនាម **នរោត្តម បុប្ផាទេវី** ដ៏ស្រស់ ទ្រង់ពេញព្រះហឫទ័យ នឹងនាដកា ជាតួអង្គរបាំអប្សរា លើកតម្កើងវប្បធម៌ពណ្ណរាយជាតិ ថ្កើងថ្កាន ល្បីល្បាញរន្ទឺទូទាំងសកលលោក ។

ជាថ្មីម្តងទៀត ទូលព្រះបង្គំជាខ្ញុំ និងភរិយា សូមវន្ទាឧទ្ទិសដល់ដួងព្រះវិញ្ញាណក្ខន្ធ**សម្តេចរាជបុត្រីព្រះរាម នរោត្តម បុប្ផាទេវី** ទ្រង់យាងយោនយកកំណើត បដិសន្ធិក្នុងសុគតិភពគ្រប់ៗជាតិ កុំឃ្លាតក្លាយជាបការៈដទៃឡើយ។

សូម **ម្លប់ម៉ែ** ជា**អម្ចាស់ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់** ទ្រង់ស្តេចទទួលនូវអភិវន្ទនៈកិច្ច និងកតញ្ញូ កតវេទិតាធម៌ដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំជាខ្ញុំនិងភរិយា ។

ថ្ងៃចន្ទ ៧រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ទីក្រុងបាងកក ព្រះរាជាណាចក្រថៃ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្តេចពិជ័យសេនា ទៀ បាញ់**